# ប្រកាសព័ត៌មាន លេខ ៣៥ (ខែ កុម្ភៈ ឆ្នាំ ២០១៧)

ក្រុមការងារគ្រប់គ្រងគម្រោង FMIS បានរៀបចំពិធី “ដាក់ឱ្យអនុវត្តគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញ-វត្ថុសាធារណៈ ជំហានទី២ ជាផ្លូវការ” កាលពីថ្ងៃទី ២២ ខែកុម្ភៈ នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានក្រុមការងារគ្រប់គ្រងគម្រោង FMIS តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, តំណាងមកពីក្រសួង-ស្ថាប័ន, គ្រប់មន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុរាជធានី-ខេត្តទាំង ២៥, គ្រប់រតនាគាររាជធានី-ខេត្ត ព្រមទាំងដៃគូអភិវឌ្ឍន៍។

នៅក្នុងខែកុម្ភៈនេះដែរ លេខាធិការដ្ឋានក្រុមការងារគ្រប់គ្រងគម្រោង FMIS បានបន្តចុះផ្សព្វផ្សាយស្តីពី “ការ-បញ្ជ្រាបការយល់ដឹងអំពីប្រព័ន្ធ FMIS” នៅតាមក្រសួង-ស្ថាប័ន ដែលនឹងចូលរួមអនុវត្តគម្រោង FMIS នៅក្នុងឆ្នាំ ២០១៧ បានចំនួន៤ក្រសួងដែលរួមមាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងសុខាភិបាល, ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និង ក្រសួងមុខងារសាធារណៈ ។ ក្រៅពីនេះក្រុមការងារក៏បានចុះទៅតាមក្រសួង-ស្ថាប័នដើម្បីសិក្សាពីនីតិវិធីអនុវត្តការងារដើម្បីចងក្រងនីតិវិធីអនុវត្តការងារបច្ចុប្បន្ន នៅតាមបណ្តាក្រសួងដែលបានធ្វើការបញ្ជ្រាបការយល់ដឹងពីប្រព័ន្ធ FMIS រួចរាល់។

ទន្ទឹមនឹងនេះ ក្រុមការងារផ្នែកគ្រប់គ្រងការផ្លាស់ប្តូរបានបន្តរៀបចំកម្មវិធីទំនាក់ទំនង និងផ្សព្វផ្សាយពីវឌ្ឍនភាព និង ធ្វើបច្ចុប្បន្នភាពព័ត៌មានរបស់គម្រោង FMIS ទៅកាន់អ្នកពាក់ព័ន្ធតាមរយៈប្រព័ន្ធផ្សព្វផ្សាយនានា និង កំពុងបន្តជួយសម្របសម្រួលជាមួយនឹងអគ្គនាយកដ្ឋានពាក់ព័ន្ធគន្លឹះទាំងអស់ ដើម្បីបញ្ចប់ការចងក្រងនីតិវិធីអនុវត្តស្តង់ដារដែលនៅសេសសល់។ ចំណែកក្រុមការងារផ្នែកមុខងារប្រព័ន្ធកំពុងបន្តជួយគាំទ្រ និង ដោះស្រាយបញ្ហាប្រឈមនានារបស់មន្ត្រីប្រើប្រាស់ប្រព័ន្ធនៅតាមរតនាគាររាជធានី-ខេត្ត ដើម្បីធ្វើយ៉ាងណាឱ្យការអនុវត្តប្រព័ន្ធកាន់តែរលូន។

ក្រុមការងារផ្នែកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មានបានចុះសិក្សា និងពិនិត្យប្លង់ និង ទីតាំងក្នុងជាជំហានដំបូងការរៀបចំហេដ្ឋារចនាសម្ព័ន្ធរបស់ប្រព័ន្ធនៅតាមបណ្តាក្រសួង-ស្ថាប័នទាំង១០ ដើម្បីត្រៀមរៀបចំការដំឡើង និងតភ្ជាប់បណ្តាញ និងឧបករណ៍ សម្រាប់ដាក់ប្រព័ន្ធ FMIS ឱ្យប្រើប្រាស់នៅក្នុងជំហានទី២ នាពេលឆាប់ៗខាងមុខនេះ ។

***ក្រុមការងារគ្រប់គ្រងគម្រោង FMIS នឹងបន្តចុះអនុវត្តសកម្មភាពទៅតាមផ្នែកនីមួយៗ ជាមួយនឹងក្រុមការងារអនុវត្តគម្រោង FMIS តាមក្រសួង-ស្ថាប័នទាំង ១០ ដែលនឹងត្រូវចូលរួមអនុវត្តគម្រោង FMIS ចាប់ពីខែកុម្ភៈនេះ។ ដូចនេះ សូមក្រុមការងារអនុវត្តគម្រោង FMIS តាមក្រសួង-ស្ថាប័នត្រៀមខ្លួនចូលរួមសហការ ដើម្បីភាពជោគជ័យនៃការអនុវត្តគម្រោង FMIS ។***

សម្រាប់ព័ត៌មានបន្ថែមផ្សេងៗ សូមចូលទៅកាន់គេហទំព័រ ឬទំនាក់ទំនងតាមអ៊ីមែល ឬទូរស័ព្ទដូចខាងក្រោម៖
គេហទំព័រ៖ http://fmis.mef.gov.kh អ៊ីមែល៖ fmis.info@mef.gov.kh ទូរស័ព្ទទំនាក់ទំនង៖ 023 430 063